CITY OF LONG BEACH PRESS RELEASE

**សេចក្ដីប្រកាសព័ត៌មាន**

ថ្ងៃទី ១ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្ដីប្រកាសជាបន្ទាន់

# សេចក្ដីជូនដំណឹងជាសាធារណៈ៖ ទីក្រុងឡុងប៊ិចផ្ដល់នូវការណែនាំអំពីវិធីការពារការរាលដាលនៃជំងឺដែលឆ្លងតាមរយៈមូស

ភ្លៀងធ្លាក់ខ្លាំងរួមផ្សំនឹងអាកាសធាតុក្ដៅបង្កើតស្ថានភាពដ៏ឥតខ្ចោះសម្រាប់ឱ្យមូសបង្កាត់ពូជ។ មន្ត្រីសុខាភិបាលទីក្រុងឡុងប៊ិចវេជ្ជបណ្ឌិតអានីសាដាវីស (Dr. Anissa Davis) ណែនាំថាប្រជាជនគួរតែអនុវត្តតាមការប្រុងប្រយ័ត្នខាងក្រោមដើម្បីការពារខ្លួនពីមូសនិងជំងឺដែលមូសអាចចម្លងបាន។

មូសអាចចម្លងជំងឺធ្ងន់ធ្ងរដូចជាមេរោគ West Nile ជំងឺរលាកខួរក្បាល ជំងឺគ្រុនចាញ់ និងមេរោគ Zika និងអាចបង្កបញ្ហាសុខភាពសាធារណៈធ្ងន់ធ្ងរ។ ប៉ុន្តែមូសមិនអាចចម្លងមេរោគកូវីដ-១៩បានទេ។

តើប្រជាជនអាចធ្វើអ្វីខ្លះដើម្បីការពារខ្លួន?

- សម្អាតធុងដែលពោរពេញទៅដោយទឹកដែលមាននៅក្នុងនិងជុំវិញផ្ទះឱ្យនៅទទេ។
- លាងសមាតទឹកងូតសម្រាប់បក្សីនិងចានទឹកសត្វចិញ្ចឹមយ៉ាងហោចណាស់ម្ដងក្នុងមួយសប្ដាហ៍។
- ចាក់ទឹកចេញពីចានដែលទ្រជើងរុក្ខជាតិ។
- ធានាថាកន្លែងលេងដែលទាក់ទងនឹងទឹក (អាងហែលទឹក, ស្លាយទឹក ល។ ) ត្រូវបានលាងសមាតឱ្យបានត្រឹមត្រូវ។
- លាងសមាតអាងហែលទឹកនិងបង្ហូរទឹកពីគម្របអាងនឹងក្លរីន។

- កំណត់ការស្រោចទឹកស្មៅនិងរុក្ខជាតិខាងក្រៅ។ អនុវត្តតាមកាលវិភាគការស្រោចទឹកនៅឡុងប៊ិចដោយស្រោចទឹកស្មៅនិងរុក្ខជាតិរបស់លោកអ្នកនៅថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍មុនម៉ោង ៩ ព្រឹកឬបន្ទាប់ពីម៉ោង ៤ ល្ងាច។
- ដំឡើងអេក្រង់នៅលើទ្វារនិងបង្អួច។
- ប្រើថ្នាំសំលាប់សត្វល្អិតដែលបានចុះក្នុងបញ្ជីនៃទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិកដូចជា DEET ដើម្បីការពារការមូសខាំ។ DEET មានសុវត្ថិភាពសម្រាប់កុមារអាយុ ២ ខែឡើងទៅក៏ដូចជាម្តាយមានផ្ទៃពោះនិងបំបៅដោះកូន (សូមប្រើតាមការណែនាំតែប៉ុណ្ណោះ)។

ការត្រួតពិនិត្យវ៉ិចទ័រ (Vector Control) និងកម្មវិធីកម្ចាត់មូសនៅតែដំណើរការក្នុងកំឡុងពេលមានបញ្ហាជំងឺកូវីដ-១៩។ ប្រជាជនត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍អំពីចំនួនមូសខាំនៅពេលថ្ងៃដែលមិនធម្មតានិងអាងដែលមិនបានត្រូវយកចិត្តទុកដាក់ឬអាងហែលទឹកមានពណ៌បៃតងដែលដុះសារាយតាមរបៀបមួយក្នុងចំណោមវិធីដូចខាងក្រោម៖

- សូមទូរស័ព្ទមកខ្សែទូរស័ព្ទបន្ទាន់នៃឡុងប៊ិចសំរាប់រាយការណ៍ពីសកម្មភាពមូសនៅលេខ 562.570.4132។
- បញ្ជូនរបាយការណ៍តាមអ៊ិនធឺរណែតនៅ www.longbeach.gov/mosquitoes។

សូមរាយការណ៍អំពីសត្វបក្សីដែលងាប់ទៅមន្ទីរសុខាភិបាលសាធារណៈរដ្ឋកាលីហ្វ័រញ៉ាដោយទូរស័ព្ទទៅលេខ 1-877-WNV-BIRD ឬតាមអ៊ិនធរណេតនៅគេហទំព័រ៖ westnile.ca.gov។

ប្រជាជនអាចស្វែងរកព័ត៌មានបន្ថែមអំពីមូស សត្វកកេរ និងចៃដោយចូលទៅកាន់គេហទំព័រ www.longbeach.gov/health និងដោយតាមដានមន្ទីរសុខាភិបាលតាមហ្វេសប៊ុក ធ្វីតធ័រ និង Instagram ។

សារព័ត៌មានអាចសាកសួរដោយផ្ទាល់ទៅកាន់លោកស្រី Judeth Luong ប្រធានស្តីទីផ្នែកសុខភាពបរិស្ថានមន្ទីរសុខាភិបាលនិងសេវាប្រជាជននៅលេខ 562.570.4104។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

សម្រាប់ព័ត៌មានបន្ថែម រូបភាព វីដេអូ និងសេចក្តីប្រកាសអំពីអ្វីដែលកំពុងកើតឡើងនៅឡុងប៊ិចសូមតាមដានទីក្រុងឡុងប៊ិចនៅលើប្រពន្ធ័ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

# # #